# កម្មវិធីវគ្គសិក្សា

# ការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក ២០០៩

ការសិក្សាបើកទូលាយ

## រៀបចំដោយ ៖

វិទ្យាស្ថានបើកទូលាយ
Open Institute

## ឧបត្ថម្ភដោយ ៖

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid

inWent
Internationale Weiterbildung und Entwicklung gGmbH

# គម្រោងមាតិកា

១. សេចក្តីផ្តើម.....3
២. គោលបំណងនៃវគ្គបណ្តុះបណ្តាល.....3
៣. លទ្ធផលរំពឹងទុក.....3
៤. លក្ខខណ្ឌសម្រាប់អ្នកដែលអាចចូលរួមសិក្សាក្នុងវគ្គនេះ.....3
៥. ខ្លឹមសាររៀន.....4
៦. យុទ្ធសាស្រ្តក្នុងការរៀន និងបង្រៀន តាមរយៈវិធីសាស្រ្តចម្រុះ.....4
៨. កាលវិភាគវគ្គសិក្សា.....6
៩. កិច្ចការត្រូវធ្វើ នៅក្នុងម៉ូឌុលនីមួយៗ.....8
១០. កាលបរិច្ឆេទផុតកំណត់ ក្នុងការបញ្ជូនកិច្ចការ.....9
១១. បញ្ជីត្រួតពិនិត្យកិច្ចការដែលត្រូវធ្វើ អំឡុងពេលរៀនលើបណ្តាញ.....9
១២. ទំនាក់ទំនងក្រុមការងារកម្មវិធីការសិក្សាបើកទូលាយ.....10

## ១. សេចក្តីផ្តើម

កម្មវិធី «ការសិក្សាបើកទូលាយ» ជាគម្រោងផ្តួចផ្តើមរួមរវាងក្រសួងអប់រំ យុវជន និង កីឡា ជាមួយនិងវិទ្យាស្ថានបើកទូលាយ បង្កើតឡើងក្នុងគោលបំណង គាំទ្រនិងជំរុញការប្រើប្រាស់ការសិក្សាតាមរយៈអេឡិចត្រូនិក នៅក្នុងប្រព័ន្ធសិក្សាអប់រំក្នុងប្រទេសកម្ពុជា ។

ការជំរុញនិងគាំទ្រអាចប្រព្រឹត្តទៅបានតាមរយៈការកសាងសមត្ថភាពជំនាញ ស្តីអំពី «ការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក» ដល់គ្រឹះស្ថានអប់រំក្នុងប្រទេស ។

## ២. គោលបំណងនៃវគ្គបណ្តុះបណ្តាល

វគ្គសិក្សា «ការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក» មានគោលបំណងផ្តល់ចំណេះដឹងគន្លឹះ វិធីសាស្ត្រ បទពិសោធន៍ជាក់ស្តែង និងបច្ចេកវិទ្យា ដើម្បីឲ្យអ្នកសិក្សាមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ ក្នុងការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក ។

វគ្គសិក្សានេះនឹងជួយអ្នកសិក្សាឲ្យអាចវិភាគ ធ្វើផែនការ អភិវឌ្ឍ និងអនុវត្តវគ្គបណ្តុះបណ្តាលដែលមានលក្ខណៈជាការសិក្សាតាមរយៈអេឡិចត្រូនិក នៅតាមស្ថាប័នសិក្សាអប់រំរបស់ខ្លួន ដោយផ្អែកទៅតាមបរិស្ថានការងារ និងតម្រូវការជាក់ស្តែង ។

## ៣. លទ្ធផលរំពឹងទុក

នៅចុងបញ្ចប់នៃវគ្គសិក្សានេះ អ្នកសិក្សានឹង ៖

- មានសមត្ថភាពជាអ្នកគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក ដោយអាច រៀបចំវគ្គសិក្សាបច្ចេកវិទ្យា បង្កើតខ្លឹមសារមេរៀន បង្រៀនលើបណ្តាញ គ្រប់គ្រងអន្តរសកម្មភាព និងការគ្រប់គ្រងវគ្គសិក្សា សម្រាប់ការសិក្សាតាមរយៈអេឡិចត្រូនិក ។
- អាចរៀបចំនិងគ្រប់គ្រងដំណើរការសិក្សាតាមរយៈអេឡិចត្រូនិកនៅតាមស្ថាប័នរបស់ខ្លួន

## ៤. លក្ខខណ្ឌសម្រាប់អ្នកដែលអាចចូលរួមសិក្សាក្នុងវគ្គនេះ

ដើម្បីអាចចូលរួមក្នុងវគ្គសិក្សានេះបាន អ្នកសិក្សាត្រូវអាចបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ចេះប្រើប្រាស់កម្មវិធីកុំព្យូទ័រការិយាល័យ សម្រាប់វាយអត្ថបទ ធ្វើការគណនា និងធ្វើបទបង្ហាញ
- ចេះប្រើប្រាស់អ៊ីមែល និងអ៊ីនធឺណិតសម្រាប់ស្វែងរកព័ត៌មាន និងទំនាក់ទំនង
- មានបទពិសោធការងារទាក់ទងទៅនឹងការរៀបចំមេរៀន ការបង្រៀន ឬរៀបចំកម្មវិធីសិក្សា ឬអ្នកដែលមានសក្តានុពលនឹងអាចក្លាយជាអ្នកគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិកបន្ទាប់ពីបញ្ចប់វគ្គសិក្សា
- មានកុំព្យូទ័រ អ៊ីនធឺណិតប្រើប្រាស់ និងរយៈពេលយ៉ាងតិច ៤ម៉ោងក្នុង១សប្តាហ៍ សម្រាប់រៀន

## ៥. ខ្លឹមសាររៀន

វគ្គសិក្សា «ការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក» សិក្សាស៊ីជម្រៅ ទៅលើម៉ូឌុលទាំង ៦ ដូចខាងក្រោមនេះ ៖




- ការរៀបចំវគ្គសិក្សា (ID)
- បច្ចេកវិទ្យាសម្រាប់ការសិក្សាតាមរយៈ អេឡិចត្រូនិក (ELT)
- ការបង្កើតខ្លឹមសាររៀន (CD)
- ការបង្រៀនសហគមន៍រៀនលើបណ្ដាញ (VLC)
- អន្តរសកម្មភាព (INT)
- ការគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក (ELM)

## ៦. យុទ្ធសាស្ត្រក្នុងការរៀន និងបង្រៀន តាមរយៈវិធីសាស្ត្រចម្រុះ

វគ្គ «ការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក» នឹងបង្រៀនជាភាសាខ្មែរ ដោយអ្នកគ្រូសម្របសម្រួលដែលមានបទពិសោធន៍ ។ យើងខ្ញុំប្រើប្រាស់វិធីសាស្ត្រចម្រុះក្នុងការបង្រៀន ដែលក្នុងនោះផ្នែកខ្លះនៃមេរៀន នឹងបង្រៀនតាមរយៈការជួបមុខគ្នាផ្ទាល់ និងផ្នែកខ្លះទៀតនៃមេរៀននឹងសម្របសម្រួលតាមរយៈអ៊ីនធឺណិត ។ រយៈពេលសរុបសម្រាប់រៀនវគ្គនេះ គឺ ១០ខែ ដែលចែកចេញជា ៣ ដំណាក់កាលគឺ ៖

| | | |
|---|---|---|
| សិក្ខាសាលា ជួបមុខគ្នាផ្ទាល់ (៤ថ្ងៃ) | រៀនលើបណ្ដាញ (៩ខែ) | សិក្ខាសាលា ជួបមុខគ្នាផ្ទាល់ (៣ថ្ងៃ) |

**សិក្ខាសាលាជួបមុខគ្នាផ្ទាល់ ពេលចាប់ផ្ដើមវគ្គសិក្សា**
**៤ថ្ងៃ ១ ថ្ងៃ ៨ម៉ោង - ចាប់ផ្ដើម ថ្ងៃទី១៦ ដល់ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩**
**ទីកន្លែង ៖ ទីស្នាក់ការអង្គការវិទ្យាស្ថានបើកទូលាយ**

សិក្ខាសាលានេះនឹងណែនាំអំពី គោលគំនិតសំខាន់ៗនៃការសិក្សាតាមរយៈអេឡិចត្រូនិក កម្មវិធីកុំព្យូទ័រ បច្ចេកវិទ្យាដែលត្រូវយកមកប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងវគ្គសិក្សា រចនាសម្ព័ន្ធមេរៀន និងគម្រោងផែនការការសិក្សាតាមរយៈអេឡិចត្រូនិក ដែលអ្នកសិក្សាត្រូវរៀបចំ និងអនុវត្ត ។

នៅក្នុងអំឡុងពេលនេះ អ្នកចូលរួមនឹងមានឱកាសពិភាក្សាផ្លាស់ប្ដូរយោបល់ ចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកដោយផ្ទាល់ បង្កើតទំនាក់ទំនងជាមួយអ្នកសិក្សាឯទៀត និងការធ្វើកិច្ចការជាក្រុម ។

**ការរៀនលើបណ្ដាញតាមរយៈអ៊ីនធឺណិត និងដោយមានការសម្របសម្រួលពីគ្រូ**
**១២៤ម៉ោង សម្រាប់៦ម៉ូឌុល ។ ១ម៉ូឌុល រៀនរយៈពេលពី ៥ ទៅ ៦សប្ដាហ៍ ។ ១សប្ដាហ៍ រៀនរយៈពេលពី ៤ ទៅ ៥ម៉ោង**

សម្រាប់ការរៀនរបៀបនេះ អ្នកសិក្សាត្រូវប្រើប្រាស់អ៊ីនធឺណិត ចូលទៅកាន់វិបផតថលការសិក្សាបើកទូលាយ (http://elearning.open.org.kh) ដែលមានខ្លឹមសារមេរៀន និងរាល់ឧបករណ៍ទំនាក់ទំនង សម្រាប់សម្របសម្រួលសកម្មភាពរៀន និងបង្រៀន ។

តាមរយៈវិបផតថលការសិក្សាបើកទូលាយ យើងនឹងប្រើប្រាស់ឧបករណ៍ និងមុខងារមួយចំនួនសម្រួលដល់ការសិក្សាដូចជា ៖ វេទិកាពិភាក្សា ការជជែក មេរៀនសម្រាប់អាន (អានលើបណ្ដាញ និងមេរៀនជាឯកសារ PDF) សទ្ទានុក្រមពាក្យបច្ចេកទេស ទីកន្លែងសម្រាប់ដាក់ស្នើកិច្ចការ ។ល។

អ្នកសិក្សាត្រូវរៀនម៉ូឌុលទាំង ៦ ជាបន្តបន្ទាប់ ដោយម៉ូឌុលនីមួយៗសិក្សារយៈពេលពី ៥ ទៅ ៦សប្ដាហ៍ ។ អ្នកសិក្សាអាចរៀនបានពីគ្រប់ទីកន្លែង និងទៅតាមពេលវេលាសមស្របរបស់ខ្លួន ។ អ្នកសិក្សាត្រូវចូលរួមក្នុងការពិភាក្សា ការជជែក និងធ្វើកិច្ចការផ្សេងៗដែលដាក់ឲ្យ ក្នុងម៉ូឌុលនីមួយៗ ។

### សិក្ខាសាលាជួបមុខគ្នាផ្ទាល់ ពេលបញ្ចប់វគ្គសិក្សា
### ៣ថ្ងៃ ១ថ្ងៃ ៨ម៉ោង - ព័ត៌មានលម្អិតនឹងផ្ដល់ជូននាពេលក្រោយ

សិក្ខាសាលានេះរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងអំពីម៉ូឌុលដែលបានរៀនលើបណ្ដាញ រៀបចំបញ្ចប់គម្រោងការសិក្សាតាមរយៈអេឡិចត្រូនិករបស់អ្នកសិក្សា និងបិទវគ្គបញ្ចប់ ។

ជាលទ្ធផលចុងក្រោយ អ្នកសិក្សាត្រូវធ្វើបទបង្ហាញជាសង្ខេប អំពីគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិករបស់ខ្លួន ។

វគ្គសិក្សានេះប្រើប្រាស់កម្មវិធីកុំព្យូទ័រប្រភេទកូដបើកចំហនិងឥតគិតថ្លៃ (Free and Open Source Software - FOSS) ដែលងាយស្រួលប្រើ ជាភាសាខ្មែរ និងអាចយកទៅប្រើប្រាស់បន្តបាននៅតាមគ្រប់គ្រឹះស្ថានអប់រំ ។ សូមចូលទៅកាន់ http://elearning.open.org.kh ដើម្បីទទួលបានព័ត៌មានលម្អិត ។

## ៧. វិញ្ញាបនបត្រ

ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា អ្នកសិក្សាទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ឲ្យបានគ្រប់ជ្រុងជ្រោយ ៖

- ចូលរួមយ៉ាងសកម្ម នៅក្នុងសិក្ខាសាលាដោយជួបមុខគ្នាផ្ទាល់ទាំងពីរលើក
- ចូលរួមប្រាស្រ័យទាក់ទងឲ្យបានទៀងទាត់ តាមរយៈសារអេឡិចត្រូនិកក្នុងអំឡុងពេលសិក្សា ក្នុងការជជែក និងការពិភាក្សាលើបណ្ដាញ
- ចូលរួមយ៉ាងសកម្មសិក្សាមេរៀនលើបណ្ដាញ និងធ្វើកិច្ចការដែលដាក់ឲ្យ
- រៀបចំនិងធ្វើការបង្ហាញអំពីគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិកពេលបញ្ចប់វគ្គសិក្សា

## ៨. កាលវិភាគវគ្គសិក្សា

| ម៉ូឌុល/ដំណាក់កាល | កាលបរិច្ឆេទ | សកម្មភាព | អ្នកសម្របសម្រួល |
| --- | --- | --- | --- |
| សិក្ខាសាលាលើកទី១ (ក្រុមទី១) | 2.3. – 5.3.<br>៤ ថ្ងៃ | • ស្វែងយល់អំពីអំពីវគ្គសិក្សាការអនុវត្តន៍និងគ្រប់គ្រងការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីវិបផតថលការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីកម្មវិធីកុំព្យូទ័រសម្រាប់ការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ការរៀបចំគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិក | ក. គង់ ស៊ីដារតន៍<br>ល. ហៃល រិទ្ធី<br>ល. លៀង ជុំសុបិន្ត<br>ល. សំ សារី |
| សិក្ខាសាលាលើកទី១ (ក្រុមទី២) | 10.3. – 13.3.<br>៤ ថ្ងៃ | • សិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីវិបផតថលការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីកម្មវិធីកុំព្យូទ័រសម្រាប់ការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ការរៀបចំគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិក | ក. គង់ ស៊ីដារតន៍<br>ល. ហៃល រិទ្ធី<br>ល. លៀង ជុំសុបិន្ត<br>ល. សំ សារី |
| សិក្ខាសាលាលើកទី១ (ក្រុមទី៣) | 16.3. – 19.3.<br>៤ ថ្ងៃ | • សិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីវិបផតថលការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ស្វែងយល់អំពីកម្មវិធីកុំព្យូទ័រសម្រាប់ការសិក្សាតាមរយៈអេឡិចត្រូនិក<br>• ការរៀបចំគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិក | ក. គង់ ស៊ីដារតន៍<br>ល. ហៃល រិទ្ធី<br>ល. លៀង ជុំសុបិន្ត<br>ល. សំ សារី |

| | | | |
|---|---|---|---|
| ការរៀបចំវគ្គសិក្សា (ID) | 30.3. – 8.5.<br>៥ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «ការរៀបចំវគ្គសិក្សា»<br>• ដោះស្រាយលំហាត់អនុវត្ត | ល. លៀង ជុំសុបិន្ត<br>ក. គង់ ស៊ីដារតន៍ |
| • សម្រាកបុណ្យចូលឆ្នាំខ្មែរ 13.4. – 17.4. (១ សប្តាហ៍)<br>• សម្រាកបុណ្យច្រត់ព្រះនង្គ័ល និងបុណ្យចម្រើនព្រះជន្មសម្តេចម៉ែ 11.5. –15.5 (១ សប្តាហ៍) | | | |
| បច្ចេកវិទ្យា (ELT) | 18.5 – 19.6.<br>៥ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «បច្ចេកវិទ្យា»<br>• បំពេញបញ្ជីត្រួតពិនិត្យ<br>• ដោះស្រាយលំហាត់អនុវត្ត | ល. លៀង ជុំសុបិន្ត<br>ក. គង់ ស៊ីដារតន៍ |
| ការបង្កើតខ្លឹមសាររៀន (CD) | 29.6. – 31.7.<br>៥ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «ការបង្កើតខ្លឹមសាររៀន»<br>• ដោះស្រាយលំហាត់អនុវត្ត | ល. សំ សារី<br>ក. គង់ ស៊ីដារតន៍ |
| សហគមន៍រៀនលើបណ្តាញ (VLC) | 10.8. – 18.9.<br>៦ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «សហគមន៍រៀនលើបណ្តាញ»<br>• ដោះស្រាយលំហាត់អនុវត្ត | ល. សំ សារី<br>ក. គង់ ស៊ីដារតន៍ |
| • សម្រាកបុណ្យភ្ជុំបិណ្ឌ 21.9. – 25.9. (១ សប្តាហ៍) | | | |
| អន្តរសកម្មភាព (INT) | 28.9. – 30.10.<br>៥ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «អន្តរសកម្មភាព»<br>• ដោះស្រាយលំហាត់អនុវត្ត | ល. លៀង ជុំសុបិន្ត<br>ក. គង់ ស៊ីដារតន៍ |
| • សម្រាកបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ 2.11. – 6.11. (១ សប្តាហ៍) | | | |
| ការគ្រប់គ្រង (ELM) | 9.11. – 11.12.<br>៥ សប្តាហ៍ | • សិក្សាទៅលើខ្លឹមសារមេរៀន<br>• បំពេញគោលគំនិត «ការគ្រប់គ្រង»<br>• ដោះស្រាយលំហាត់អនុវត្ត | ក. គង់ ស៊ីដារតន៍<br>ល. លៀង ជុំសុបិន្ត |

| | | | |
|---|---|---|---|
| សិក្ខាសាលាលើកទី២ | ធ្នូ ២០០៩<br>៣ ថ្ងៃ | • ការរំលឹកអំពីម៉ូឌុលទាំង៦<br>• រៀបចំ និងបង្ហាញគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិក<br>• បូកសរុបលទ្ធផលសិក្សា<br>• វាយតម្លៃវគ្គបណ្តុះបណ្តាល<br>• ពិធីប្រគល់វិញ្ញាបនបត្រ | ក. គង់ ស៊ីដារតន៍<br>ល. ហៃល រិទ្ធី<br>ល. លៀង ជុំសុបិន្ត<br>ល. សំ សារី |

## ៩. កិច្ចការត្រូវធ្វើ នៅក្នុងម៉ូឌុលនីមួយៗ

| សប្តាហ៍ | កិច្ចការត្រូវធ្វើ នៅក្នុងម៉ូឌុលមួយ |
|---|---|
| **សប្តាហ៍ទី១** | • អានសេណារីយោ<br>• អានមេរៀនលើបណ្តាញ<br>• ចូលរួមក្នុងវេទិកាពិភាក្សា |
| **សប្តាហ៍ទី ២** | • អានមេរៀនលើបណ្តាញ<br>• ចូលរួមការជជែក និងវេទិកាពិភាក្សា |
| **សប្តាហ៍ទី ៣** | • អានមេរៀនលើបណ្តាញ<br>• ចូលរួមការជជែក និងវេទិកាពិភាក្សា<br>• ចាប់ផ្តើមធ្វើកិច្ចការ |
| **សប្តាហ៍ទី ៤** | • អានមេរៀនលើបណ្តាញ<br>• ចូលរួមការជជែក និងវេទិកាពិភាក្សា<br>• បញ្ជូនលទ្ធផលកិច្ចការទៅឲ្យគ្រូ (ផុតកំណត់ ៖ ថ្ងៃច័ន្ទ សប្តាហ៍ទី៥) |
| **សប្តាហ៍ទី ៥** | • អានមតិយោបល់ត្រឡប់របស់គ្រូ ដែលបានផ្តល់ឲ្យចំពោះកិច្ចការ<br>• លៃតម្រូវលទ្ធផលកិច្ចការ ទៅតាមមតិយោបល់ត្រឡប់របស់គ្រូ<br>• បញ្ជូនកិច្ចការជាថ្មីម្តងទៀត<br>• ឆ្លើយសំណួរបញ្ចប់ម៉ូឌុល<br>• វាយតម្លៃម៉ូឌុលដែលបានសិក្សា |

ចំណាំ ៖ ប្រសិនបើអ្នកសិក្សាអវត្តមានជាប់គ្នា រយៈពេលចាប់ពី ៣ថ្ងៃឡើងទៅ អ្នកសិក្សាត្រូវជូនដំណឹងដល់គ្រូសម្របសម្រួល ឲ្យបានមុនយ៉ាងហោចណាស់ ២ថ្ងៃ ដោយប្រកាសអំពីការអវត្តមាននេះ នៅក្នុងវេទិកាជូនដំណឹងរបស់ម៉ូឌុលសិក្សា ។

## ១០. កាលបរិច្ឆេទផុតកំណត់ ក្នុងការបញ្ជូនកិច្ចការ

គ្រូសម្របសម្រួលម៉ូឌុលនីមួយៗ នឹងណែនាំអ្នកសិក្សា អំពីរបៀបធ្វើកិច្ចការរបស់ម៉ូឌុលនីមួយៗ ព្រមទាំងជួយរំលឹកអំពីកាលបរិច្ឆេទផុតកំណត់នៃកិច្ចការនីមួយៗ ។ គ្រូនឹងផ្តល់ព័ត៌មានត្រឡប់ចំពោះលទ្ធផលកិច្ចការរបស់អ្នកសិក្សាម្នាក់ៗ ។

បញ្ជីខាងក្រោមនេះ បង្ហាញអំពីកាលបរិច្ឆេទផុតកំណត់ ក្នុងការបញ្ជូនកិច្ចការទៅឲ្យគ្រូ ។ បញ្ជីនេះក៏បង្ហាញអំពីកាលបរិច្ឆេទចុងក្រោយ ដែលគ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ផងដែរ ។

| | | |
|---|---|---|
| ការរៀបចំវគ្គសិក្សា (ID) | (30.3. – 8.5.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 27.4.<br>មតិយោបល់ត្រឡប់ ៖ 4.5. |
| បច្ចេកវិទ្យា (ELT) | (18.5. – 19.6.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 8.6.<br>មតិយោបល់ត្រឡប់ ៖ 15.6. |
| ការបង្កើតខ្លឹមសាររៀន (CD) | (29.6. – 31.7.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 20.7.<br>មតិយោបល់ត្រឡប់ ៖ 27.7. |
| សហគមន៍រៀនលើបណ្តាញ (VLC) | (10.8. – 18.9.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 7.9.<br>មតិយោបល់ត្រឡប់ ៖ 14.9. |
| អន្តរសកម្មភាព (INT) | (28.9. – 30.10.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 19.10.<br>មតិយោបល់ត្រឡប់ ៖ 26.10. |
| ការគ្រប់គ្រង (ELM) | (9.11. – 11.12.) | ផុតកំណត់បញ្ជូនកិច្ចការ ៖ 30.11.<br>មតិយោបល់ត្រឡប់ ៖ 7.12. |

**សម្គាល់ ៖** សូមព្យាយាមបញ្ជូនកិច្ចការ ឲ្យទាន់តាមពេលកំណត់ ដើម្បីឲ្យអ្នកសិក្សាអាចទទួលបានមតិត្រលប់ពីគ្រូទាន់ពេលវេលា ហើយអ្នកសិក្សាក៏អាចមានពេលវេលាគ្រប់គ្រាន់ក្នុងការកែតម្រូវកិច្ចការរបស់ខ្លួន ទៅតាមព័ត៌មានត្រឡប់ទាំងនោះ !

## ១១. បញ្ជីត្រួតពិនិត្យកិច្ចការដែលត្រូវធ្វើ អំឡុងពេលរៀនលើបណ្តាញ

ខាងក្រោមនេះគឺជាបញ្ជីកិច្ចការត្រូវធ្វើ នៅក្នុងដំណាក់កាលរៀនលើបណ្តាញ ។ អ្នកសិក្សាអាចយកបញ្ជីនេះធ្វើជាបញ្ជីត្រួតពិនិត្យ ៖ ដោយធីកកិច្ចការណា ដែលបានបំពេញចប់រួចរាល់ ហើយសម្រាប់កិច្ចការណាដែលមិនទាន់បានបំពេញ អ្នកសិក្សាត្រូវព្យាយាមបំពេញឲ្យរួចរាល់ ។

| កាលបរិច្ឆេទ | កិច្ចការ | ធីក |
|---|---|---|
| កិច្ចការដែលទាក់ទងនឹងគម្រោងការសិក្សាតាមរយៈអេឡិចត្រូនិករបស់អ្នកសិក្សា | | |
| 27.4. | កិច្ចការនៃវគ្គការរៀបចំវគ្គសិក្សា ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |
| 8.6. | កិច្ចការនៃវគ្គបច្ចេកវិទ្យា ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |

| | | |
|---|---|---|
| 20.7. | កិច្ចការនៃវគ្គការបង្កើតខ្លឹមសាររៀន ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |
| 7.9. | កិច្ចការនៃវគ្គការបង្រៀនលើបណ្ដាញ ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |
| 19.10. | កិច្ចការនៃវគ្គអន្តរសកម្មភាព ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |
| 30.11. | កិច្ចការនៃវគ្គការគ្រប់គ្រង ៖ ផ្នែកទី១ គោលគំនិត; ផ្នែកទី២ លំហាត់ | ☐ |
| ការសិក្សាមេរៀន និងការប្រាស្រ័យទាក់ទងនៅក្នុងម៉ូឌុលនីមួយៗ | | |
| អានមេរៀន | អានមេរៀនឲ្យបានចប់សព្វគ្រប់ នៅក្នុងម៉ូឌុលនីមួយៗ | ☐ |
| វេទិកា | ចូលរួមពិភាក្សានៅក្នុងវេទិកាឲ្យបានយ៉ាងហោចណាស់ចំនួន៣ដងទៅលើប្រធានបទខុសៗគ្នា | ☐ |
| ការជជែក | ចូលរួមក្នុងការជជែក ៖ ចូលរួមពិភាក្សានៅក្នុងការជជែក ឲ្យបានយ៉ាងហោចណាស់ ១ដង នៅក្នុង ១ម៉ូឌុល ។ | ☐ |
| ចែករំលែកវិបសាយដែលមានប្រយោជន៍ | ផ្ដល់អាសយដ្ឋានវិបសាយដែលមានប្រយោជន៍ ឲ្យបានយ៉ាងហោចណាស់១វិបសាយក្នុង១ម៉ូឌុល | ☐ |
| ចែករំលែកឯកសារដែលមានប្រយោជន៍ | បញ្ជូនឯកសារស្រាវជ្រាវដែលមានប្រយោជន៍ទៅកាន់វិបផតថលការសិក្សាតាមរយៈអេឡិចត្រូនិក ឲ្យបានយ៉ាងហោចណាស់ ១ឯកសារ | ☐ |
| ការចូលរួមធ្វើការជាក្រុម | ចូលរួមធ្វើការងារជាក្រុម ឬចូលរួមលេងល្បែងកម្សាន្តលើបណ្ដាញ ដែលគ្រូអាចនឹងរៀបចំឲ្យធ្វើ ។ | ☐ |
| ទំនាក់ទំនងជាមួយគ្រូសម្របសម្រួល | ឧស្សាហ៍ទាក់ទងជាមួយគ្រូតាមរយៈសារអេឡិចត្រូនិក (យ៉ាងហោចណាស់ ជូនដំណឹងដល់គ្រូអំពីការបញ្ចប់កិច្ចការ បញ្ជីត្រួតពិនិត្យ ឬលំហាត់អនុវត្ត) រយៈពេលសមរម្យក្នុងការឆ្លើយតបចំពោះសារអេឡិចត្រូនិកគឺ យ៉ាងយូរ ៣ថ្ងៃ | ☐ |
| | ត្រូវជូនដំណឹងឲ្យបានឆាប់រហ័សអំពីការអវត្តមាន ក្នុងករណីមានធុរៈមិនអាចចូលរួមការជជែក ឬកិច្ចពិភាក្សាផ្សេងៗ នៅអំឡុងពេលរៀនលើបណ្ដាញ | ☐ |

## ១២. ទំនាក់ទំនងក្រុមការងារកម្មវិធីការសិក្សាបើកទូលាយ

**លោក សុខ ថា**
ក្រសួងអប់រំ យុវជន និង កីឡា
ការិយាល័យព័ត៌មានវិទ្យាអប់រំ
សហអ្នកសម្របសម្រួលគម្រោង
ទូរស័ព្ទ ៖ ០១១ ៩០១ ៩០១
សារអេឡិចត្រូនិក ៖soktha@moeys.gov.kh

**កញ្ញា គង់ ស៊ីដារតន៍**
អង្គការវិទ្យាស្ថានបើកទូលាយ
កម្មវិធីការសិក្សាបើកទូលាយ
សហអ្នកសម្របសម្រួលគម្រោង
ទូរស័ព្ទ ៖ ០១២ ៧៨៣ ២៦២
សារអេឡិចត្រូនិក ៖ da@open.org.kh

**លោក លៀង ជុំសុបិន្ត**
អ្នកជំនួយការអ្នកសម្របសម្រួលគម្រោង
ទូរស័ព្ទ ៖ ០១៦ ៣២៣៦២៣
សារអេឡិចត្រូនិក ៖ leang.chumsoben@open.org.kh

**លោក ហ៊ែល រិទ្ធី**
អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល
ទូរស័ព្ទ ៖ ០១៧ ៩៦២៥៩៦
សារអេឡិចត្រូនិក hr_rithy@open.org.kh

**លោក សំ សារី**
គ្រូបង្គោល
ទូរស័ព្ទ ៖ ០១២ ៣១៦៨២៧
សារអេឡិចត្រូនិក samsary@open.org.kh

**ក្រសួងអប់រំ យុវជន និង កីឡា** ៖ # ៨០ មហាវិថីព្រះនរោត្តម

**អង្គការវិទ្យាស្ថានបើកទូលាយ** ៖ ផ្ទះលេខ ១៩ ផ្លូវលេខ ៣៧៤ (ទល់មុខសាលាសង្កាត់ទួលស្វាយព្រៃ១)
សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ។

*(ភ្នំពេញ មីនា ២០០៩)*